**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ០៦៤/១៦ ក.អ.ជ.ប្រក

ថ្ងៃ សុក្រ ១២កើត ខែ មាឃ ឆ្នាំ មមែ ព.ស. ២៥៥៩
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ គ.ស. ២០១៦

# ប្រកាស
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្ម និងគណៈកម្មការវាយតម្លៃឯកសារដេញថ្លៃរបស់គម្រោងកែលម្អផ្លូវជនបទជំហានទី ២

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងប្រកាសលេខ ១៦០/១៤ ក.អ.ជ. ប្រក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើត និងតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការសម្រាប់គណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មរបស់គម្រោងកែលម្អផ្លូវជនបទជំហានទី ២
- យោងប្រកាសលេខ ១៥៤/១៥ ក.អ.ជ.ប្រក ចុះថ្ងៃទី ២០ ខែកក្កដា គ.ស. ២០១៥ ស្តីពីការកែសម្រួលសមាសភាពអង្គភាពគ្រប់គ្រងគម្រោងកែលម្អផ្លូវជនបទជំហានទី ២ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងហិរញ្ញប្បទានពីមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចកូរ៉េ (EDCF)
- យោងប្រកាសលេខ ១៥៦/១៥ ក.អ.ជ. ប្រក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មរបស់គម្រោងកែលម្អផ្លូវជនបទជំហានទី ២

- យោងកំណត់ហេតុកិច្ចប្រជុំចរចាឥណទានរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ១.-** កែសម្រួលសមាសភាពគណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មសម្រាប់គម្រោងកែលម្អផ្លូវជនបទ ជំហានទី ២ ដូចខាងក្រោម÷

ក. គណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មកម្រិតធំ

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម | **សួស គង់** | ជាប្រធាន |
| ២. | ឯកឧត្តម | **ចាន់ ដារ៉ុខ** | ជាសមាជិក |
| ៣. | លោក | **ដោក ជូម៉ា** | ជាសមាជិក |
| ៤. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២ រូប | | ជាសមាជិក |

ខ. គណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មកម្រិតមធ្យម

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម | **ចាន់ ដារ៉ុខ** | ជាប្រធាន |
| ២. | លោក | **ដោក ជូម៉ា** | ជាសមាជិក |
| ៣. | លោក | **ខួន តារា** | ជាសមាជិក |
| ៤. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២ រូប | | ជាសមាជិក |

គ. គណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មកម្រិតតូច

| | | | |
|---|---|---|---|
| ១. | លោក | **ដោក ជូម៉ា** | ជាប្រធាន |
| ២. | លោក | **ង៉ែ សំអាត** | ជាសមាជិក |
| ៣. | កញ្ញា | **គង់ សុជាតា** | ជាសមាជិក |
| ៤. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២ រូប | | ជាសមាជិក |

ឃ. គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទិញ និងកិច្ចការសំណង់ (BEC)

| | | | |
|---|---|---|---|
| ១. | លោក | **ស្រ៊ន់ ពិធូ** | ជាប្រធាន |
| ២. | លោក | **ឈា ទើខហ៊ុយ** | ជាសមាជិក |
| ៣. | លោក | **ពៅ្យម សុគ័ន្រ្ត** | ជាសមាជិក |

ង. គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនផ្តល់សេវា (CEC) កម្រិតធំ

| | | | |
|---|---|---|---|
| ១. | លោក | **សុខ សុផល** | ជាប្រធាន |
| ២. | លោក | **ឈា ទើខហ៊ុយ** | ជាសមាជិក |



k

៣. លោក **សាន ទិសាល** ជាសមាជិក

៤. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២ រូប ជាសមាជិក

ច. គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនផ្តល់សេវា (CEC) កម្រិតមធ្យម

១. លោក **សុខ សុផល** ជាប្រធាន

២. លោក **ឈា ទ័េចហ៊ុយ** ជាសមាជិក

៣. លោក **សាន ទិសាល** ជាសមាជិក

៤. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២ រូប ជាសមាជិក

ឆ. គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនផ្តល់សេវា (CEC) កម្រិតតូច

១. លោក **ឈា ទ័េចហ៊ុយ** ជាប្រធាន

២. លោក **ស្រ៊ន់ ពិធូ** ជាសមាជិក

៣. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២ រូប ជាសមាជិក

**ប្រការ ២.-** មន្ត្រីរាជការដូចមានក្នុងប្រការ ១ មានភារកិច្ចទទួលខុសត្រូវ ដឹកនាំ ត្រួតពិនិត្យកិច្ចការលទ្ធកម្ម គម្រោងកែលម្អផ្លូវជនបទជំហានទី ២ ។

**ប្រការ ៣.-** សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឆាយ សុផារ៉ា**

<u>***កន្លែងទទួល***</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-មន្ទីរពាក់ព័ន្ធ*
*"ដើម្បីជូនជ្រាប"*
*-ដូចប្រការ ៤*
*"ដើម្បីអនុវត្ត"*
*-ឯកសារ - កាលប្បវត្តិ*